# ជំហាន៤យ៉ាង នៃវិធានការជំនួយបឋមក្នុងការព្យាបាលជំងឺហឺត



## 1

ដាក់អ្នកជំងឺអង្គុយឱ្យត្រង់ខ្លួន



## 2

ផ្តល់ថ្នាំព្យាបាលជំងឺហឺត ក្នុងបំពង់ហឺតពណ៌ខៀវ /ពណ៌ប្រផេះ ៤ដងដាច់ដោយឡែកពីគ្នា

- ក្រឡុកបំពង់ហឺត
- បាញ់ថ្នាំចូលក្នុងបំពង់ស្រូប១ដង
- ស្រូបថ្នាំ៤ដង្ហើម ចេញពីបំពង់ស្រូប

ធ្វើឡើងវិញ រហូតទាល់តែស្រូបអស់ថ្នាំដែលបាញ់ចូល៤ដង

សូមចងចាំ៖ ក្រឡុក បាញ់ថ្នាំចូល១ដង ស្រូបថ្នាំ៤ដង្ហើម

ឬផ្តល់ថ្នាំ Bricanyl ក្នុងបំពង់ហឺត២ដងដាច់ដោយឡែកពីគ្នា (សម្រាប់កុមារអាយុ៦ឆ្នាំ និងច្រើនជាង)
ឬថ្នាំ Symbicort ក្នុងបំពង់ហឺត (សម្រាប់មនុស្សអាយុលើសពី១២ឆ្នាំឡើងទៅ)




## 3

សូមរង់ចាំ៤នាទី

ប្រសិនបើមិនធូរស្រាលទេ សូមផ្តល់ថ្នាំព្យាបាលជំហឺហឺត ក្នុងបំពង់ហឺតពណ៌ខៀវ / ពណ៌ប្រផេះ ៤ដងបន្ថែមទៀត ដាច់ដោយឡែកពីគ្នាដូចខាងលើ

ឬផ្តល់ថ្នាំ Bricanyl ឬ Symbicort ក្នុងបំពង់ហឺត ១ដងទៀត




## 4

ប្រសិនបើនៅតែមិនធូរស្រាលទេ សូមទូរស័ព្ទ សូន្យបីដង (000) សម្រាប់ហៅឡានពេទ្យ

បន្តផ្តល់ថ្នាំ៤ដងដាច់ដោយឡែកពីគ្នា រៀងរាល់៤នាទី រហូតទាល់តែជំនួយសង្គ្រោះបន្ទាន់មកដល់

ឬផ្តល់ថ្នាំ Bricanyl ឬ Symbicort ១ដង រៀងរាល់៤នាទី - រហូតដល់ទៅ៣ដងថែមទៀតនៃថ្នាំ Symbicort

### ទូរស័ព្ទហៅជំនួយសង្គ្រោះបន្ទាន់ភ្លាមៗ។ វាយលេខសូន្យបីដង (000):

- ប្រសិនបើអ្នកជំងឺមិនដកដង្ហើម។
- ប្រសិនបើជំងឺហឺតរបស់អ្នកជំងឺ រឹតកាន់តែធ្ងន់ធ្ងរយ៉ាងឆាប់រហ័ស ឬមិនធូរស្រាលទេ។
- ប្រសិនបើអ្នកជំងឺកំពុងកើតជំងឺហឺតខ្លាំងក្លា ហើយពុំអាចរកបំពង់ហឺតបាន។
- ប្រសិនបើអ្នកពុំប្រាកដថាវាជាជំងឺហឺតទេ។
- ប្រសិនបើអ្នកជំងឺនោះត្រូវបានគេស្គាល់ថា មានប្រតិកម្មអាលែកហ្ស៊ីធ្ងន់ធ្ងរ (anaphylaxis) – ត្រូវអនុវត្តតាមផែនការសកម្មភាពព្យាបាលប្រតិកម្មអាលែកហ្ស៊ីធ្ងន់ធ្ងររបស់អ្នកជំងឺ បន្ទាប់មកផ្តល់ជំនួយបឋមក្នុងការព្យាបាលជំងឺហឺត។ ថ្នាំព្យាបាលជំងឺហឺតក្នុងបំពង់ហឺតពណ៌ខៀវ/ពណ៌ប្រផេះ ពុំទំនងបង្កគ្រោះថ្នាក់ឡើយ ទោះបីជាបុគ្គលនោះមិនមានជំងឺហឺតក៏ដោយ។

ការពារខ្លួនអ្នកនៅរដូវសម្បូរលំអងផ្កានេះ។
ការគ្រប់គ្រងជំងឺហឺត និងអាលែកហ្ស៊ីមានសារៈសំខាន់។
បើកចូលវ៉ិបសៃ betterhealth.vic.gov.au ឬហៅទូរស័ព្ទលេខ 1800 ASTHMA (1800 278 462) សម្រាប់ព័ត៌មានបន្ថែម។

អនុញ្ញាត និងបោះពុម្ពផ្សាយដោយ រដ្ឋាភិបាលវិចតូរីយ៉ា 1 Treasury Place, Melbourne (1708026)
© រដ្ឋវិចតូរីយ៉ា (Department of Health and Human Services)។
លើកលែងតែនិមិត្តសញ្ញា បានទទួលអាជ្ញាប័ណ្ណនៅក្រោមអាជ្ញាប័ណ្ណរបស់ CC BY International 4.0។

ASTHMA AUSTRALIA

VICTORIA State Government